ភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩

# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ការចុះហត្ថលេខាលើហិរញ្ញប្បទានឥតសំណងសម្រាប់ "គម្រោងអាហារូបករណ៍អភិវឌ្ឍធនធានមនុស្ស (JDS)"

នាថ្ងៃសុក្រ ទី២៨ ខែមិថុនា ឆ្នាំ២០១៩ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) បានចុះហត្ថលេខាលើហិរញ្ញប្បទានឥតសំណងសម្រាប់ "គម្រោងអាហារូបករណ៍អភិវឌ្ឍធនធានមនុស្ស (JDS)" ប្រកបដោយជោគជ័យ។

ហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងនេះគឺមានទំហំទឹកប្រាក់សរុប ៣៣៩ លានយ៉េន ក្នុងគោលបំណងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សក្នុងប្រទេសកម្ពុជា តាមរយៈការផ្តល់ឱកាសដល់មន្ត្រីវ័យក្មេងរបស់កម្ពុជានូវអាហារូបករណ៍ សម្រាប់បន្តការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅសាកលវិទ្យាល័យនានាក្នុងប្រទេសជប៉ុន។ ទន្ទឹមនឹងនេះ នៅពេលដែលនិស្សិតអាហារូបករណ៍ JDS បានបញ្ចប់ការសិក្សានិងត្រឡប់មកប្រទេសកម្ពុជាវិញ ពួកគេនឹងមានឱកាសក្នុងការចូលរួមអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច តាមរយៈការចូលរួមបង្កើតគោលនយោបាយនិងអនុវត្តន៍គោលនយោបាយសង្គមនិងសេដ្ឋកិច្ចផ្សេងៗ។

គម្រោងអាហារូបករណ៍អភិវឌ្ឍធនធានមនុស្ស (JDS) បានចាប់ផ្តើមក្នុងឆ្នាំ ២០០០ ក្នុងប្រទេសកម្ពុជា។ រហូតមកដល់បច្ចុប្បន្ន មាននិស្សិតអាហារូបករណ៍ JDS ចំនួន ៤១៦នាក់ បានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសជប៉ុន ហើយពួកគេកំពុងបម្រើការងារក្នុងវិស័យនិងស្ថាប័នផ្សេងៗទូទាំងប្រទេសកម្ពុជា។ សម្រាប់ឆ្នាំនេះ មាននិស្សិតអាហារូបករណ៍ JDS សរុបចំនួន ២៤នាក់ ត្រូវបានជ្រើសរើសទៅសិក្សាថ្នាក់អនុបណ្ឌិត និងចំនួន ២នាក់ ទៅសិក្សាថ្នាក់បណ្ឌិតនៅប្រទេសជប៉ុន។

<u>សំរាប់ព័ត៌មានបន្ថែម</u> សូមទំនាក់ទំនងលោក ស៊ុន វាសនា មន្ត្រីការិយាល័យ JICA ប្រចាំនៅកម្ពុជា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៦៧៣/៤ ឬ ០១២ ៨៥១ ៤៤៤ អ៊ីម៉ែល Soun-Veasna@jica.go.jp.